PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

# កម្រងសំណួរ-ចម្លើយសំខាន់ៗទាក់ទងនឹងកញ្ចប់ផលិតផល PRUសុខភាពខ្ញុំ

## លក្ខណ:សម្បត្តិរបស់ផលិតផល៖

1. **តើអ្វីទៅជាកញ្ចប់ PRUសុខភាពខ្ញុំ?**
កញ្ចប់ **PRUសុខភាពខ្ញុំ** ជាកញ្ចប់ផលិតផលធានារ៉ាប់រងដែលក្នុងនោះរួមមានផលិតផលធានារ៉ាប់រងមូលដ្ឋាន **PRUអ្នកការពារ** ដែលផលិតផលនេះផ្តល់ការការពារទៅលើករណីមរណភាព ឬពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ភ្ជាប់ជាមួយផលិតផលធានារ៉ាប់រងបន្ថែម **PRUសុខភាពខ្ញុំ** ដែលផ្តល់ការការពារទៅលើករណីមានការកើតឡើងនូវជំងឺ ឬការព្យាបាលណាមួយដែលមិនបានព្រាងទុក ដូចជាការព្យាបាលជំងឺមហារីក ការសម្រាកព្យាបាលដែលមិនមែនជាការព្យាបាលជំងឺមហារីក ការព្យាបាលដោយមិនចាំបាច់សម្រាកនៅមន្ទីរពេទ្យ (ការវះកាត់ក្នុងថ្ងៃ និង ការលាងឈាម) និងផលវិបាកនៃការមានគភ៌ ។

2. **តើអតិថិជនណាខ្លះដែលអាចជាវកញ្ចប់ផលិតផល PRUសុខភាពខ្ញុំ?**
អតិថិជនដែលអាចជាវកញ្ចប់ផលិតផលនេះរួមមាន៖
ក. នីតិបុគ្គលដែលបានចុះបញ្ជី និងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា **ឬ**
ខ.រូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬ កំពុងរស់នៅក្នុងប្រទេសកម្ពុជាយ៉ាងតិចណាស់ 6 ខែ ដោយមាន អាសយដ្ឋានពិតប្រាកដនៅប្រទេសកម្ពុជា និងមានអាយុចាប់ពី 18 ទៅ 60 ឆ្នាំ។

3. **តើអត្ថប្រយោជន៍របស់កញ្ចប់ផលិតផល PRUសុខភាពខ្ញុំ មានអ្វីខ្លះ?**
កញ្ចប់ផលិតផល **PRUសុខភាពខ្ញុំ** ផ្តល់ជូនអត្ថប្រយោជន៍ធានារ៉ាប់រងថ្លៃ ព្យាបាលសុខភាព ទៅតាមទីតាំងភូមិសាស្ត្រផ្សេងៗដោយផ្អែកលើគម្រោងដែលលោកអ្នកបានជ្រើសរើស។ ការការពារនេះផ្អែកលើថ្លៃចំណាយវេជ្ជសាស្ត្រជាក់ស្តែងបន្ទាប់ពីទូទាត់ការចូលរួមចំណែកក្នុងការចំណាយ (co-payment) និង ទៅតាមតារាងទំហំអត្ថប្រយោជន៍រងកំណត់តាមផ្នែកនីមួយៗ ដូចតារាងអត្ថប្រយោជន៍ដែលបានបង្ហាញដូចខាងក្រោម ។

| អត្ថប្រយោជន៍ (ជាដុល្លារអាមេរិក ក្នុងមួយឆ្នាំបណ្ណសន្យារ៉ាប់រង) | | គម្រោងទី 1<br>សំរឹទ្ធ | គម្រោងទី 2<br>ប្រាក់ | គម្រោងទី 3<br>មាស | គម្រោងទី 4<br>ពេជ្រ |
|---|---|---|---|---|---|
| ទីតាំងភូមិសាស្ត្រ | | ប្រទេសកម្ពុជា | ប្រទេសកម្ពុជា វៀតណាម និង ថៃ | ប្រទេសក្នុងតំបន់អាស៊ានលើកលែងសិង្ហបុរី | ប្រទេសក្នុងតំបន់អាស៊ាន |
| ទំហំអត្ថប្រយោជន៍ប្រចាំឆ្នាំសរុប[1] (អនុវត្តទៅលើចំណុចទី 1 ដល់ 4) | | 5,000 | 10,000 | 30,000 (ទំហំអត្ថប្រយោជន៍រងសម្រាប់ប្រទេសកម្ពុជា10,000) | 50,000 (ទំហំអត្ថប្រយោជន៍រងសម្រាប់ប្រទេសកម្ពុជា10,000) |
| ចំនួនអតិបរមានៃការចូលរួមចំណែកក្នុងការចំណាយ (20%) ក្នុង ១ ហេតុការណ៍[2] | | 100 | 150 | 500 | 700 |
| 1 | ការព្យាបាលជំងឺមហារីក | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | 1.1 | ការសម្រាកព្យាបាលជំងឺមហារីកដោយសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងមិនសម្រាកនៅមន្ទីរពេទ្យ(រួមមានការព្យាបាលដោយប្រើគីមី ការព្យាបាលដោយកាំរស្មី ការព្យាបាលដោយកំណត់គោលដៅ) (មិនមានទំហំអត្ថប្រយោជន៍តាមប្រភេទប៉ុន្តែទំហំអត្ថប្រយោជន៍ថ្លៃបន្ទប់ និងការស្នាក់នៅ អនុវត្តតាមចំណុច 1.2) | រហូតដល់ទំហំអត្ថប្រយោជន៍រងប្រចាំឆ្នាំសរុប | រហូតដល់ទំហំអត្ថប្រយោជន៍រងប្រចាំឆ្នាំសរុប | រហូតដល់ទំហំអត្ថប្រយោជន៍រងប្រចាំឆ្នាំសរុប | រហូតដល់ទំហំអត្ថប្រយោជន៍រងប្រចាំឆ្នាំសរុប |
| | 1.2 | ថ្លៃបន្ទប់ និង ការស្នាក់នៅជាក់ស្តែង (ច្រើនបំផុតត្រឹម 80 ថ្ងៃ រួមបញ្ចូលអត្ថប្រយោជន៍ប្រពោធនកម្ម) | 25 | 50 | 250 | 500 |
| **2** | **ការសម្រាកព្យាបាល ដែលមិនមែនជាការព្យាបាលជំងឺមហារីក<br>ទំហំអត្ថប្រយោជន៍រង (លើកលែងជំងឺមហារីក)** | | | | | |
| | 2.1 | ថ្លៃបន្ទប់ និង ការស្នាក់នៅជាក់ស្តែង (ច្រើនបំផុតត្រឹម 80 ថ្ងៃ រួមបញ្ចូលអត្ថប្រយោជន៍ប្រពោធនកម្ម) | 25 | 50 | 250 | 500 |
| | 2.2 | ថ្លៃចំណាយជាក់ស្តែងផ្នែកប្រពោធនកម្មក្នុងមួយថ្ងៃ(ច្រើនបំផុតត្រឹម៣០ថ្ងៃ) | 50 | 100 | 500 | 1,000 |
| | 2.3 | ថ្លៃចំណាយជាក់ស្តែងទៅលើការវះកាត់ដោយសម្រាកនៅមន្ទីរពេទ្យ | 500 | 1,000 | 10,000 | 25,000 (10,000 សម្រាប់កម្ពុជា) |
| | 2.4 | ថ្លៃចំណាយជាក់ស្តែងទៅលើការព្យាបាលមុនពេលចូលសម្រាកនៅមន្ទីរពេទ្យ (រហូតដល់៣០ថ្ងៃមុនថ្ងៃចូលសម្រាកមន្ទីរពេទ្យ) | 100 | 250 | 500 | 1,000 |
| | 2.5 | ថ្លៃចំណាយជាក់ស្តែងទៅលើការព្យាបាលក្រោយពេលចាកចេញពីមន្ទីរពេទ្យច្រើនបំផុតត្រឹម 5 ដង (60 ថ្ងៃបន្ទាប់ពីចេញពីមន្ទីរពេទ្យ) | 100 | 250 | 500 | 1,000 |
| | 2.6 | ថ្លៃចំណាយជាក់ស្តែងទៅលើសេវាក្នុងមន្ទីរពេទ្យ និងសេវាពាក់ព័ន្ធផ្សេងៗ | 1,000 | 2,000 | 6,000 | 10,000 |
| | 2.7 | ថ្លៃចំណាយជាក់ស្តែងទៅលើរថយន្តសង្គ្រោះបន្ទាន់ | 50 | 100 | 300 | 500 |
| **3** | **ការព្យាបាលដោយមិនចាំបាច់សម្រាកនៅមន្ទីរពេទ្យ** | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | 3.1 | ថ្លៃចំណាយជាក់ស្តែងទៅលើលើការវះកាត់ក្នុងថ្ងៃ | 100 | 200 | 500 | 2,000 |
| | 3.2 | ថ្លៃចំណាយជាក់ស្តែងទៅលើការលាងឈាម | 500 | 1,000 | 3,000 | 5,000 |
| 4 | **ផលវិបាកនៃការមានគភ៌ (អ្នកត្រូវបានធានារ៉ាប់រងត្រូវតែមានអាយុចាប់ពី 20-49 ឆ្នាំ)** | | | | | |
| | 4.1 | ថ្លៃសម្រាកព្យាបាលនៅឬមិននៅមន្ទីរពេទ្យជាក់ស្តែង (រយៈពេលរង់ចាំ ៣៦៥ថ្ងៃ) | 500 | 1,000 | 3,000 | 5,000 |
| 5 | **PRUអ្នកការពារ[4] (អត្ថប្រយោជន៍បន្ថែមទៅលើករណីមរណភាព ឬ ពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍)** | | | | | |
| | 5.1 | ករណីមរណភាព ឬ ពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍[3](ដោយមូលហេតុណាមួយ) | 5,000 | 10,000 | 30,000 | 50,000 |

**កំណត់ចំណាំ៖**

1. ទំហំអត្ថប្រយោជន៍ប្រចាំឆ្នាំសរុបគឺជាចំនួនទឹកប្រាក់អតិបរមាទូទាត់សម្រាប់ការចំណាយវេជ្ជសាស្ត្រដែលកើតឡើងសម្រាប់សេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រក្នុងអំឡុងមួយឆ្នាំបណ្ណសន្យារ៉ាប់រង។ ទំហំអត្ថប្រយោជន៍រង គឺជាការចំណាយជាអតិបរមាទៅលើប្រភេទនៃការចំណាយវេជ្ជសាស្ត្រនីមួយៗដែលកើតឡើងសម្រាប់សេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រក្នុងអំឡុងមួយឆ្នាំបណ្ណសន្យារ៉ាប់រង។
2. ការចូលរួមចំណែកក្នុងការចំណាយ គឺជាចំនួនទឹកប្រាក់នៃថ្លៃព្យាបាលជាក់ស្តែង ដែលម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវទទួលខុសត្រូវក្នុងការបង់សម្រាប់ព្រឹត្តិការណ៍ធានារ៉ាប់រងនីមួយៗ។ទំនួលខុសត្រូវរបស់អ្នកត្រូវបានធានារ៉ាប់រងក្នុងការចូលរួមចំណែកក្នុងការចំណាយ អាចលើសពីចំនួនទឹកប្រាក់កំណត់ នៅពេលដែលការទាមទារសំណងសម្រាប់ប្រភេទនៃការចំណាយវេជ្ជសាស្ត្រនីមួយៗ លើសពីទំហំអត្ថប្រយោជន៍រង។
3. ក្នុងករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ក្នុងអំឡុងពេល ឬ បន្ទាប់ពីពេលចាកចេញពី មន្ទីរពេទ្យ អត្ថប្រយោជន៍នៃការចំណាយវេជ្ជសាស្ត្រសម្រាប់ការព្យាបាលចុងក្រោយ នៅមុនពេលមានការបញ្ជាក់ពីមរណភាព ឬ ពិការភាពទាំងស្រុង និង ជាអចិន្ត្រៃយ៍ដោយវេជ្ជបណ្ឌិត នឹងអាចទាមទារសំណងបាន។ បណ្ណសន្យារ៉ាប់រងនឹងត្រូវបញ្ចប់ បន្ទាប់ពីការទូទាត់អត្ថប្រយោជន៍មរណភាព ឬ ពិការទាំងស្រុង និងជាអចិន្ត្រៃយ៍។
4. កញ្ចប់**PRUសុខភាពខ្ញុំ** គឺរួមបញ្ចូលជាមួយ ធានារ៉ាប់រងបន្ថែម**PRUសុខភាពខ្ញុំ**ភ្ជាប់មកជាមួយកញ្ចប់មូលដ្ឋាន**PRUអ្នកការពារ**។

### 4. តើខ្ញុំអាចជាវកញ្ចប់ផលិតផល PRUសុខភាពខ្ញុំ បានតាមវិធីណា?

អតិថិជនអាចជាវកញ្ចប់ផលិតផលនេះតាមរយៈ៖

ក. ទីប្រឹក្សាធានារ៉ាប់រងអាយុជីវិត (LC)

ខ. ទីប្រឹក្សាហិរញ្ញវត្ថុ(FC)នៅតាមធនាគារអេស៊ីលីដា (ACLEDA) ទូទាំងប្រទេសកម្ពុជា

គ. ផ្ញើសារមកតាមរយៈគេហទំព័រព្រូដិនសល គេហទំព័រហ្វេសប៊ុកផ្លូវការ ឬទំនាក់ទំនងមកកាន់ផ្នែកសេវាកម្មអតិថិជនរបស់ក្រុមហ៊ុនព្រូដិនសលតាមរយៈលេខទូរស័ព្ទ 023 964 222 ឬ 1800-212223 (ឥតគិតថ្លៃ)។

### 5. តើករណីមិនធានារបស់កញ្ចប់ផលិតផល PRUសុខភាពខ្ញុំ មានអ្វីខ្លះ?

**ករណីមិនធានារបស់ផលិតផលធានារ៉ាប់រងមូលដ្ឋាន PRUអ្នកការពារ -** ករណីមរណភាព ឬ ពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ដោយសារគ្រោះថ្នាក់ចៃដន្យ និងមិនមែនគ្រោះថ្នាក់ចៃដន្យ៖

ក្រុមហ៊ុននឹងបដិសេធក្នុងការទូទាត់អត្ថប្រយោជន៍ដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើការទាមទារសំណងរបស់អ្នកត្រូវបានធានារ៉ាប់រងត្រូវបានកើតឡើងដូចលក្ខខណ្ឌណាមួយខាងក្រោម៖

ក. ការធ្វើឱ្យរបួសខ្លួនឯង ការធ្វើអត្តឃាត ឬការប៉ុនប៉ងធ្វើអត្តឃាត

ខ. មេរោគអេដស៍ និង/ឬ ជំងឺណាមួយដែលជាប់ទាក់ទងនឹងមេរោគអេដស៍

គ. ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ

ឃ. ការប្រើគ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន

**ករណីមិនធានារបស់ផលិតផលធានារ៉ាប់រងបន្ថែម PRUសុខភាពខ្ញុំ៖**

បន្ថែមពីលើករណីមិនធានាដូចបានរៀបរាប់ក្នុងចំណុចខាងលើ ក្រុមហ៊ុននឹងបដិសេធក្នុងការទូទាត់សំណងព្យាបាលវេជ្ជសាស្ត្រ ដែលកើតឡើងដូចលក្ខខណ្ឌណាមួយខាងក្រោម៖

ក. ស្ថានភាព ឬ ជំងឺមានពីមុនស្រាប់
ខ. ការព្យាបាលទៅលើភាពមិនប្រក្រតីពីកំណើត
គ. ការមានគភ៌ ឬ ផលវិបាកនៃការមានគភ៌ ក្រៅពីស្ថានភាពជាក់លាក់ដែលត្រូវបានធានារ៉ាប់រង
ឃ. ការព្យាបាលទៅលើអសមត្ថភាពផ្លូវភេទ ឬ ការគ្មានកូន
ង. ការព្យាបាលបែបឯកជន ជំងឺអេដស៍ ឬ មេរោគ HIV ជំងឺទាក់ទងនឹងជំងឺអេដស៍ និងជំងឺឆ្លងណាមួយដែលតម្រូវដោយច្បាប់ឲ្យនៅដាច់ពីគេ
ច. ជំងឺវិកលចរិក ជំងឺផ្លូវចិត្ត ឬ ជំងឺខ្លាច
ឆ. ការរងរបួសដែលមកពីការចូលរួមសកម្មភាពដែលប្រឈមនឹងគ្រោះថ្នាក់
ជ. ការប៉ុនប៉ងធ្វើអត្តឃាត ការធ្វើអត្តឃាត ឬ ធ្វើឲ្យរបួសខ្លួនឯង
ឈ. ការប្រព្រឹត្ត ឬ ការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ
ញ. ការព្យាបាលពីអ្នកអនុវត្តវេជ្ជសាស្ត្រដែលជាសាច់ញាតិ
ដ. សង្គ្រាម ការរំលោភបំពាន ការបំលែងកាំរស្មី ភេរវកម្ម
ឋ. ការព្យាបាលដែលមិនមានភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ (រួមបញ្ចូលការពិនិត្យកាយសម្បទាជាប្រចាំ ការព្យាបាលនឹងការគ្មានកូន ការវះកាត់កែសម្ផស្ស ការព្យាបាលមាត់ធ្មេញ ការចាក់ប្រព័ន្ធភាពស៊ាំ ជាដើម)
ឌ. ការធ្វើដំណើរតាមផ្លូវអាកាសជាលក្ខណៈឯកជន ដែលមិនមែនជាអ្នកដំណើរដែលត្រូវបង់ប្រាក់ថ្លៃធ្វើដំណើរ
សម្រាប់ព័ត៌មានលម្អិតចំពោះករណីមិនធានា សូមអានឯកសារបណ្ណសន្យារ៉ាប់រងបន្ថែម។

6. **តើមានការពិនិត្យសុខភាពនៅក្នុងដំណើរការចេញបណ្ណសន្យារ៉ាប់រងចំពោះកញ្ចប់ផលិតផល PRUសុខភាពខ្ញុំ ដែរឬទេ?**

អតិថិជនគឺតម្រូវឲ្យឆ្លងកាត់ដំណើរការចេញបណ្ណសន្យារ៉ាប់រង ដែលដំណើរការនេះផ្អែកទៅតាមគោលការណ៍នៃដំណើរការចេញបណ្ណសន្យារ៉ាប់រងរបស់ក្រុមហ៊ុនព្រូដិនសល ដើម្បីកំណត់ថាអតិថិជននឹងតម្រូវឲ្យធ្វើការពិនិត្យសុខភាពដែរឬទេ។

7. **តើរយៈពេលរង់ចាំរបស់កញ្ចប់ផលិតផលនេះមានលក្ខណៈយ៉ាងដូចម្តេច ?**

ការទាមទារសំណងនឹងមិនត្រូវបានផ្តល់ជូនឡើយក្នុងករណីជំងឺ ឬ របួសណាក៏ដោយដែលបានកើតឡើង ឬត្រូវបានធ្វើរោគវិនិច្ឆ័យ ក្នុងអំឡុងរយៈពេលរង់ចាំ ឬកើតឡើងក្រោយពេលបញ្ចប់រយៈពេលរង់ចាំ ប៉ុន្តែករណីនោះទាក់ទងនឹងស្ថានភាពជំងឺឬរបួសដែលកើតឡើងហើយ ឬត្រូវបានធ្វើរោគវិនិច្ឆ័យរួចរាល់មុនឬក្នុងអំឡុងរយៈពេលរង់ចាំ។

ក. សម្រាប់ការព្យាបាលដោយសារគ្រោះថ្នាក់ចៃដន្យ មានរយៈពេលរង់ចាំចំនួន 1 (មួយ) ថ្ងៃ។
ខ. សម្រាប់ការព្យាបាលដោយសារជំងឺជាក់លាក់ដែលបានកំណត់ មានរយៈពេលរង់ចាំ 120 (មួយរយម្ភៃ) ថ្ងៃ។
គ. សម្រាប់ផលវិបាកនៃការមានគភ៌ មានរយៈពេលរង់ចាំ 365 (បីរយហុកសិបប្រាំ) ថ្ងៃ។
ឃ. សម្រាប់ការព្យាបាលដោយសារជំងឺផ្សេងៗ លើកលែងជំងឺជាក់លាក់ដែលបានកំណត់ មានរយៈពេលរង់ចាំ 30 (សាមសិប) ថ្ងៃ។

សម្រាប់ព័ត៌មានលម្អិតចំពោះជំងឺជាក់លាក់ដែលបានកំណត់ និង ផលវិបាកនៃការមានគភ៌ សូមអានឯកសារបណ្ណសន្យារ៉ាប់រងបន្ថែម។

8. **តើអតិថិជនដែលមានអាយុចន្លោះពី 61-69 អាចទិញកញ្ចប់ផលិតផល PRUសុខភាពខ្ញុំ បានដែរឬទេ?**
ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវតែមានអាយុយ៉ាងតិច 18 ឆ្នាំដើម្បីអាចដាក់ពាក្យស្នើសុំបណ្ណសន្យារ៉ាប់រង។ ប៉ុន្តែអាយុអ្នកត្រូវបានធានារ៉ាប់រងនៃផលិតផល **PRUសុខភាពខ្ញុំ** គឺត្រូវចាប់ផ្តើមពីអាយុ10-60 ឆ្នាំ និង អាចបន្តសុពលភាពរហូតដល់អាយុ 70 ឆ្នាំ។

9. **ក្នុងករណីដែលអតិថិជនបានជាវផលិតផលចំនួន២កញ្ចប់ ហើយកញ្ចប់ទី១ត្រូវបានប្រើប្រាស់អស់ទំហំអត្ថប្រយោជន៍ តើអតិថិជនអាចប្រើប្រាស់អត្ថប្រយោជន៍នៃកញ្ចប់ទី២បានដែរឬទេ?**

អ្នកត្រូវបានធានារ៉ាប់រងម្នាក់អាចមានបណ្ណសន្យារ៉ាប់រងតែមួយប៉ុណ្ណោះ។

10. **ប្រសិនបើជាមានករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ក្នុងអំឡុងពេលដំណើរការចេញបណ្ណសន្យារ៉ាប់រង តើអតិថិជនអាចធ្វើការទាមទារសំណងបានដែរឬទេ?**
អតិថិជនអាចធ្វើការទាមទារសំណងបានទៅលើអត្ថប្រយោជន៍ដែលស្ថិតជាទម្រង់ធានារ៉ាប់រងបណ្តោះអាសន្ន ដែលអត្ថប្រយោជន៍នេះគិតចាប់ពីថ្ងៃដែលក្រុមហ៊ុនបានទទួលពាក្យស្នើសុំ និងបុព្វលាភធានារ៉ាប់រងដំបូង។ អត្ថប្រយោជន៍ធានារ៉ាប់រងបណ្តោះអាសន្ននេះមានទឹកប្រាក់ចំនួន 2,500 ដុល្លារអាមេរិក ដែលផ្តល់ជូនអ្នកត្រូវបានធានារ៉ាប់រងចម្បងទៅលើករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារគ្រោះថ្នាក់ចៃដន្យ។

## ការទាមទារសំណង៖

11. **តើខ្ញុំអាចដាក់សំណើទាមទារសំណងយ៉ាងដូចម្តេច?**
ការដាក់ស្នើទាមទារសំណងសម្រាប់កញ្ចប់ផលិតផល **PRUសុខភាពខ្ញុំ** មានពីររបៀប ដែលលោកអ្នកអាចធ្វើកាទាមទារសំណងមកវិញ (Reimbursed Claim) ឬ ជ្រើសរើសការទូទាត់សំណងដោយផ្ទាល់ (Direct Billing) តាមរយៈភ្នាក់ងារដៃគូទូទាត់សំណងរបស់ក្រុមហ៊ុនព្រូដិនសល គឺ South Asia Service (Third-Party Administrator/South Asia Service) ៖

ក. ការទាមទារសំណងមកវិញ (Reimbursed Claim) គឺជាការទាមទារសំណងក្នុងករណីដែលលោកអ្នកទទួលសេវាកម្មវេជ្ជសាស្ត្រជាមួយមន្ទីរពេទ្យ ឬស្ថាប័នដែលមិនមែនជាដៃគូរបស់ក្រុមហ៊ុន។ លោកអ្នកនឹងត្រូវធ្វើការទូទាត់ថ្លៃចំណាយវេជ្ជសាស្ត្រដោយផ្ទាល់ជាមួយមន្ទីរពេទ្យ បន្ទាប់មកទើបធ្វើការដាក់សំណើទាមទារសំណងជាមួយក្រុមហ៊ុនព្រូដិនសល ឬ ភ្នាក់ងារដៃគូទូទាត់សំណងរបស់ក្រុមហ៊ុនព្រូដិនសល South Asia Service (Third-Party Administrator/South Asia Service) តាមក្រោយ។

ខ. ការទូទាត់សំណងដោយផ្ទាល់(Direct Billing) គឺជាការទាមទារសំណងក្នុងករណីដែលលោកអ្នកទទួលសេវាកម្មវេជ្ជសាស្ត្រជាមួយមន្ទីពេទ្យ ឬស្ថាប័នដែលជាដៃគូរបស់ក្រុមហ៊ុន។ (ចំណាំ៖ អតិថិជនចាំបាច់តម្រូវឲ្យធ្វើនិតិវិធីនៃការស្នើសុំការអនុញ្ញាតជាមុន)។

***កំណត់សម្គាល់៖*** *នីតិវិធីស្នើសុំការអនុញ្ញាតជាមុន ជាដំណើរការមួយដែលអ្នកត្រូវបានធានារ៉ាប់រងទទួលបានការយល់ព្រមពីក្រុមហ៊ុនសម្រាប់ការព្យាបាលផ្នែកវេជ្ជសាស្ត្រជាក់លាក់ណាមួយ មុននឹងការចាប់ផ្តើមការព្យាបាលនោះ។*

12. **តើការព្យាបាលផ្នែកវេជ្ជសាស្ត្រណាខ្លះ ដែលចាំបាច់តម្រូវឲ្យមាននិតិវិធីនៃការស្នើសុំការអនុញ្ញាតជាមុន?**

ការព្យាបាលវេជ្ជសាស្ត្រដែលតម្រូវឲ្យស្នើសុំការអនុញ្ញាតជាមុន ពីក្រុមហ៊ុន ឬ ភ្នាក់ងារដៃគូទូទាត់សំណងរបស់ក្រុមហ៊ុនព្រូដិនសល South Asia Service មានដូចរៀបរាប់ខាងក្រោម ៖

ក. ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ

ខ. ការវះកាត់ដោយសម្រាកនៅមន្ទីរពេទ្យ

ឃ. ការវះកាត់ក្នុងថ្ងៃ

**នៅក្នុងករណីបន្ទាន់ មិនមានការតម្រូវឲ្យស្នើសុំការអនុញ្ញាតជាមុនឡើយ តែអ្នកត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងមកក្រុមហ៊ុនព្រូដិនសល ឬ ភ្នាក់ងារដៃគូទូទាត់សំណងរបស់ក្រុមហ៊ុនព្រូដិនសល South Asia Service ក្នុងរយៈពេល 48 (សែសិបប្រាំបី) ម៉ោង គិតចាប់ពីពេលហេតុការណ៍បន្ទាន់កើតឡើង។*

13. **តើការទំនាក់ទំនងតាមរយៈទូរស័ព្ទ ឬការផ្ញើសារ អាចចាត់ទុកជានិតិវិធីនៃការស្នើសុំការអនុញ្ញាតជាមុនដែរឬទេ?**
អតិថិជនអាចធ្វើការទំនាក់ទំនងតាមរយៈទូរស័ព្ទ ឬការផ្ញើសារបានតែក្នុងករណីបន្ទាន់តែប៉ុណ្ណោះ។ (ចំពោះការព្យាបាលដែលមានការត្រៀមទុកជាមុនចាំបាច់តម្រូវឲ្យមាននិតិវិធីនៃការស្នើសុំការអនុញ្ញាតជាមុនទៅដល់ក្រុមហ៊ុនព្រូដិនសល ឬ ភ្នាក់ងារដៃគូទូទាត់សំណងរបស់ក្រុមហ៊ុនព្រូដិនសល South Asia Service ។

14. **តើការស្នើសុំទាមទារសំណងមកវិញ (Reimbursed claim) តម្រូវឲ្យមានឯកសារអ្វីខ្លះ?**
ឯកសារសម្រាប់ការទាមទារសំណងមានដូចខាងក្រោម៖

ក. ទម្រង់បែបបទនៃការទាមទារសំណង

ខ. ការបញ្ជាក់ពីវេជ្ជបណ្ឌិត

គ. ច្បាប់ដើមនៃវិក័យបត្រចំណាយវេជ្ជសាស្ត្រ

ឃ. លិខិតពីគ្រូពេទ្យព្យាបាល

ង. របាយការណ៍រោគសាស្ត្រឬរបាយណ៍ការច្រឹបសាច់ឬរបាយណ៍ការជាលិកាសាស្ត្រ

ច. លិខិតចម្លងគណនីធនាគារ

ឆ. អត្តសញ្ញាណប័ណ្ណរបស់អតិថិជន

ជ. ឯកសារបន្ថែមទៀត ប្រសិនបើចាំបាច់

15. **តើការទូទាត់សំណងដោយផ្ទាល់តម្រូវឲ្យមានឯកសារអ្វីខ្លះ?**
ចំពោះការទូទាត់សំណងដោយផ្ទាល់គឺមិនតម្រូវឲ្យលោកអ្នកដាក់សំណើទាមទារសំណងនោះទេ ប៉ុន្តែលោកអ្នកចាំបាច់ភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដើម្បីទទួលបានការអនុញ្ញាតសម្រាប់ការសម្រាកព្យាបាល៖

ក. អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ឬសំបុត្រកំណើត (ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងជាអនីតិជនដែលមិនទាន់មានឯកសារសម្គាល់ដូចជាអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន)

ខ. កាតធានារ៉ាប់រងឬ កញ្ចប់បណ្ណសន្យារ៉ាប់រងអេឡិចត្រូនិច

អំឡុងពេលចាកចេញពីមន្ទីរពេទ្យ អតិថិជនមានតួនាទីទូទាត់ការចូលរួមចំណែកក្នុងការចំណាយ (co-payment) និងចំណាយផ្សេងទៀត (បើមាន) ដែលលើសឬមិនស្ថិតក្នុងការធានារ៉ាប់រងនៅក្នុងបណ្ណសន្យារ៉ាប់រង។

16. **ក្នុងករណីដែលការព្យាបាលមិនទាន់ត្រូវបានបញ្ចប់ ប៉ុន្តែបណ្ណសន្យារ៉ាប់រងអស់សុពលភាព ហើយអតិថិជនជ្រើសរើសមិនបន្តសុពលភាពបណ្ណសន្យារ៉ាប់រងម្តងទៀត តើអតិថិជនអាចដាក់សំណើទាមទារសំណងបានដែរឬទេ?**
អតិថិជននៅតែបន្តទទួលបានអត្ថប្រយោជន៍នៃការសម្រាកព្យាបាល។ អត្ថប្រយោជន៍ធានារ៉ាប់រង នឹងត្រូវបានគិតចាប់ពីថ្ងៃដែលការព្យាបាលបានធ្វើឡើងក្នុងអំឡុងពេលបណ្ណសន្យារ៉ាប់រងមានសុពលភាព រហូតដល់ការព្យាបាលត្រូវបាន

បញ្ចប់ ទោះបីជាបណ្ណសន្យារ៉ាប់រងបានផុតកាលបរិច្ឆេទក៏ដោយ។ អត្ថប្រយោជន៍ធានារ៉ាប់រងនេះនឹងត្រូវបានផ្តល់ជូនដោយផ្អែកទៅតាមតារាងអត្ថប្រយោជន៍ដែលបានបង្ហាញដូចខាងក្រោម ។

| អត្ថប្រយោជន៍ (ជាដុល្លារអាមេរិក ក្នុងមួយឆ្នាំបណ្ណសន្យារ៉ាប់រង) | | | គម្រោងទី 1 | គម្រោងទី 2 | គម្រោងទី 3 | គម្រោងទី 4 |
|---|---|---|---|---|---|---|
| | | | សំរឹទ្ធ | ប្រាក់ | មាស | ពេជ្រ |
| ទីតាំងភូមិសាស្ត្រ | | | ប្រទេសកម្ពុជា | ប្រទេសកម្ពុជា វៀតណាម និងថៃ | ប្រទេសក្នុងតំបន់អាស៊ានលើកលែងសិង្ហបុរី | ប្រទេសក្នុងតំបន់អាស៊ាន |
| ទំហំអត្ថប្រយោជន៍ប្រចាំឆ្នាំសរុប (អនុវត្តទៅលើចំណុចទី 1 ដល់ 4) | | | 5,000 | 10,000 | 30,000 (ទំហំអត្ថប្រយោជន៍រងសម្រាប់ប្រទេសកម្ពុជា10,000) | 50,000 (ទំហំអត្ថប្រយោជន៍រងសម្រាប់ប្រទេសកម្ពុជា10,000) |
| ចំនួនអតិបរមានៃការចូលរួមចំណែកក្នុងការចំណាយ (20%) ក្នុង ១ ហេតុការណ៍ | | | 100 | 150 | 500 | 700 |
| **1** | **ការព្យាបាលជំងឺមហារីក** | | | | | |
| | 1.1 | ការសម្រាកព្យាបាលជំងឺមហារីកដោយសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងមិនសម្រាកនៅមន្ទីរពេទ្យ(រួមមានការព្យាបាលដោយប្រើគីមី ការព្យាបាលដោយកាំរស្មី ការព្យាបាលដោយកំណត់គោលដៅ) (មិនមានទំហំអត្ថប្រយោជន៍តាមប្រភេទប៉ុន្តែទំហំអត្ថប្រយោជន៍ថ្លៃបន្ទប់ និងការស្នាក់នៅ អនុវត្តតាមចំណុច 1.2) | ត្រូវបានផ្តល់ជូនចំពោះតែអត្ថប្រយោជន៍នៃការសម្រាកព្យាបាល | | | |
| | 1.2 | ថ្លៃបន្ទប់ និង ការស្នាក់នៅជាក់ស្តែង (ច្រើនបំផុតត្រឹម 80 ថ្ងៃ រួមបញ្ចូលអត្ថប្រយោជន៍ប្រពោធនកម្ម) | ត្រូវបានផ្តល់ជូន | | | |
| **2** | **ការសម្រាកព្យាបាល ដែលមិនមែនជាការព្យាបាលជំងឺមហារីក ទំហំអត្ថប្រយោជន៍រង (លើកលែងជំងឺមហារីក)** | | | | | |
| | 2.1 | ថ្លៃបន្ទប់ និង ការស្នាក់នៅជាក់ស្តែង (ច្រើនបំផុតត្រឹម 80 ថ្ងៃ រួមបញ្ចូលអត្ថប្រយោជន៍ប្រពោធនកម្ម) | ត្រូវបានផ្តល់ជូន | | | |
| | 2.2 | ថ្លៃចំណាយជាក់ស្តែងផ្នែកប្រពោធនកម្មក្នុងមួយថ្ងៃ(ច្រើនបំផុតត្រឹម៣០ថ្ងៃ) | ត្រូវបានផ្តល់ជូន | | | |
| | 2.3 | ថ្លៃចំណាយជាក់ស្តែងទៅលើការវះកាត់ដោយសម្រាកនៅមន្ទីរពេទ្យ | ត្រូវបានផ្តល់ជូន | | | |

| | | | |
|---|---|---|---|
| | 2.4 | ថ្លៃចំណាយជាក់ស្តែងទៅលើការព្យាបាលមុនពេលចូលសម្រាកនៅមន្ទីរពេទ្យ (រហូតដល់៣០ថ្ងៃមុនថ្ងៃចូលសម្រាកមន្ទីរពេទ្យ) | ត្រូវបានផ្តល់ជូន |
| | 2.5 | ថ្លៃចំណាយជាក់ស្តែងទៅលើការព្យាបាលក្រោយពេលចាកចេញពីមន្ទីរពេទ្យច្រើនបំផុតត្រឹម 5 ដង (60 ថ្ងៃបន្ទាប់ពីចេញពីមន្ទីពេទ្យ) | មិនត្រូវបានផ្តល់ជូន |
| | 2.6 | ថ្លៃចំណាយជាក់ស្តែងទៅលើសេវាក្នុងមន្ទីរពេទ្យ និងសេវាពាក់ព័ន្ធផ្សេងៗ | ត្រូវបានផ្តល់ជូន |
| | 2.7 | ថ្លៃចំណាយជាក់ស្តែងទៅលើរថយន្តសង្គ្រោះបន្ទាន់ | មិនត្រូវបានផ្តល់ជូន |
| **3** | **ការព្យាបាលដោយមិនចាំបាច់សម្រាកនៅមន្ទីរពេទ្យ** | | |
| | 3.1 | ថ្លៃចំណាយជាក់ស្តែងទៅលើលើការវះកាត់ក្នុងថ្ងៃ | មិនត្រូវបានផ្តល់ជូន |
| | 3.2 | ថ្លៃចំណាយជាក់ស្តែងទៅលើការលាងឈាម | មិនត្រូវបានផ្តល់ជូន |
| **4** | **ផលវិបាកនៃការមានគភ៌ (អ្នកត្រូវបានធានារ៉ាប់រងត្រូវតែមានអាយុចាប់ពី 20-49 ឆ្នាំ)** | | |
| | 4.1 | ថ្លៃសម្រាកព្យាបាលនៅឬមិននៅមន្ទីរពេទ្យជាក់ស្តែង (រយៈពេលរង់ចាំ ៣៦៥ថ្ងៃ) | ត្រូវបានផ្តល់ជូនចំពោះតែអត្ថប្រយោជន៍នៃការសម្រាកព្យាបាល |

**17. តើខ្ញុំអាចទាក់ទងដើម្បីទទួលបានការគាំទ្រចំពោះការទាមទារសំណងរបស់ខ្ញុំបានយ៉ាងដូចម្តេច?**

សម្រាប់ជំនួយលើសេវាកម្ម និង សំណួរផ្សេងៗ លោកអ្នកអាចទាក់ទងទៅកាន់៖

ក. ភ្នាក់ងារដៃគូទូទាត់សំណងរបស់ក្រុមហ៊ុនព្រូដិនសល South Asia Service

សម្រាប់ព័ត៌មានទូទៅ៖
-លេខទូរស័ព្ទ៖ 015 555 192 (24ម៉ោង/7ថ្ងៃ)
-អ៊ីម៉ែល៖ kh-inquiry@southasiaservices.com
សម្រាប់សេវាកម្មទៅលើការទូទាត់សំណងដោយផ្ទាល់ (Direct Billing)៖
-លេខទូរស័ព្ទ៖ 081 888 959 (24ម៉ោង/7ថ្ងៃ)
-អ៊ីម៉ែល៖ kh-directbilling@southasiaservices.com

ខ. ក្រុមការងារទាមទារសំណងរបស់ក្រុមហ៊ុនព្រូដិនសលកម្ពុជា៖

-លេខទូរស័ព្ទ៖ 095 964 222 (ក្នុងម៉ោងការងារ)
-អ៊ីម៉ែល៖ pcla.claims@prudential.com.kh

**18. តើអតិថិជនត្រូវទូទាត់ថ្លៃនៃការចូលរួមចំណែកក្នុងការចំណាយ (co-payment) នៅពេលណា?**

ក. សម្រាប់ការទាមទារសំណងមកវិញ (Reimbursed Claim) អតិថិជននឹងត្រូវចេញថ្លៃចំណាយវេជ្ជសាស្ត្រដោយខ្លួនឯងរួចជាមុន ហើយបន្ទាប់មកទើបធ្វើការដាក់សំណើទាមទារសំណងជាមួយក្រុមហ៊ុនព្រូដិនសល។ ក្រុមហ៊ុនព្រូដិនសលនឹងទូទាត់ជូនសំណងដែលអតិថិជនមានសិទ្ធិក្នុងការទទួលបាន ដោយដកចេញនូវចំនួននៃថ្លៃក្នុងការចូលរួមចំណែកក្នុងការចំណាយ (co-payment)។

ខ. សម្រាប់ការទូទាត់សំណងដោយផ្ទាល់ (Direct Billing) អតិថិជននឹងត្រូវធ្វើការទូទាត់នូវការចូលរួមចំណែកក្នុងការចំណាយ (co-payment) ដែលវាត្រូវបានរួមបញ្ចូលជាមួយថ្លៃចំណាយដែលនៅសល់ នៅអំឡុងពេលចាកចេញពីមន្ទីរពេទ្យ ទៅកាន់មន្ទីរពេទ្យដែលជាដៃគូ។ ការទូទាត់សំណងនឹងផ្អែកទៅលើទំហំអត្ថប្រយោជន៍ប្រចាំឆ្នាំសរុប និងទំហំអត្ថប្រយោជន៍រងដែលមានក្នុងគម្រោងនៃបណ្ណសន្យារ៉ាប់រងរបស់លោកអ្នក។

## ការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ និងការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង៖

**19. ក្នុងករណីដែលអតិថិជនបានផ្អាកបង់បុព្វលាភធានារ៉ាប់រង ហើយបណ្ណសន្យារ៉ាប់រងក្លាយជាអស់សុពលភាពចាប់ពីរយៈពេល ១ឆ្នាំ តើអតិថិជនអាចបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញបានដែរឬទេ ?**

អតិថិជនមិនអាចបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញបានទេក្នុងករណីនេះ ប៉ុន្តែអតិថិជនអាចធ្វើការស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញក្នុងរយៈពេល 6 (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងនោះអស់សុពលភាពជាបណ្ដោះអាសន្នតែប៉ុណ្ណោះ។ ប្រសិនបើពុំមានការស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញក្នុងរយៈពេល 6 (ប្រាំមួយ) ខែ ដូចរៀបរាប់ខាងលើនោះទេ បណ្ណសន្យារ៉ាប់រងរបស់លោកអ្នកនឹងត្រូវបានបញ្ចប់។

**20. តើដំណើការការបញ្ចប់បណ្ណសន្យារ៉ាប់រង សម្រាប់កញ្ចប់ផលិតផល PRUសុខភាពខ្ញុំ ប្រព្រឹត្តទៅយ៉ាងដូចម្ដេច?**

បណ្ណសន្យារ៉ាប់រងនឹងត្រូវលុបចោលដោយស្វ័យប្រវត្តិ នៅពេលដែលហេតុការណ៍ណាមួយខាងក្រោមកើតឡើង៖

ក. មរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រងនៅក្រោមបណ្ណសន្យារ៉ាប់រង ឬ

ខ.បន្ទាប់ពីក្រុមហ៊ុនបានទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រងទាំងអស់ ដោយផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនៃផលិតផលធានារ៉ាប់រងនេះ ឬ

គ.បន្ទាប់ពីទទួលបានសំណើរបស់ម្ចាស់បណ្ណសន្យារ៉ាប់រងក្នុងការបោះបង់បណ្ណសន្យារ៉ាប់រងនៃផលិតផលធានារ៉ាប់រង ឬ

ឃ. ដល់ថ្ងៃផុតកំណត់នៃរយៈពេលកំណត់នៃការធានារ៉ាប់រង ឬ

ង. បន្ទាប់ពីអ្នកត្រូវបានធានារ៉ាប់រងឈានចូលអាយុ 70 ឆ្នាំ (អាយុថ្ងៃខួបកំណើតចុងក្រោយ) ឬ

ច. ក្រុមហ៊ុនបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ ដោយផ្អែកលើបណ្ណសន្យារ៉ាប់រងនៃកិច្ចសន្យាធានារ៉ាបរង ឬ

ឆ. ស្ថានភាពផ្សេងទៀត ដូចដែលមានចែងក្នុងច្បាប់ធានារ៉ាប់រងជាធរមាន និង/ឬ បទប្បញ្ញត្តិពាក់ព័ន្ធ ឬ

ជ. ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការលុបចោលបណ្ណសន្យារ៉ាប់រង ឬ បដិសេធលើការស្នើសុំទាមទារសំណង ករណីម្ចាស់បណ្ណសន្យារ៉ាប់រង និង អ្នកត្រូវបានធានារ៉ាប់រង ក្រោមបណ្ណសន្យារ៉ាប់រងនេះ ផ្ដល់ព័ត៌មានមិនពិត ឬ មិនត្រឹមត្រូវ ដែលមានសារៈសំខាន់សម្រាប់ធ្វើការវាយតម្លៃអំពីហានិភ័យ ដើម្បីចេញបណ្ណសន្យារ៉ាប់រង និងការធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះ។

******************************